# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jun-2012, 13:42
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## ការជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការស្រាវជ្រាវនៅ DC-CAM

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រំ ផល្លា

Scarlet WAGNER
Devika KAMP

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី**

**Pich Ang**
**Elisabeth SIMONNEAU-FORT**

## I. សេចក្តីផ្តើម

១. មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះសូមដាក់ការជូនដំណឹង ("ការជូនដំណឹង") ដល់អង្គជំនុំជម្រះសាលាដំបូងថា ក្រុមមេធាវីការពារក្តីនឹងធ្វើការស្រាវជ្រាវនៅមជ្ឈមណ្ឌល DC-CAM។ ក្រុមមេធាវីការពារក្តីសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថាខ្លួនព្យាយាមត្រួតពិនិត្យខ្សែរសង្វាក់នៃការរក្សា និងប្រភពនៃឯកសារទាំងនេះ ដែល កសព មានបំណងយកមកសំអាង[1] ។

## II. ប្រវត្តិនីតិវិធី

### ក. ការស្រាវជ្រាវដោយឯករាជ្យដោយក្រុមមេធាវីការពារក្តី

២. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២00៨ កសចស បានជូនដំណឹងមកក្រុមមេធាវីការពារក្តីថា ក្រុមមេធាវីមិនត្រូវបានអនុញ្ញាតឲ្យដំណើរការស៊ើបសួរណាមួយដោយខ្លួនឯងទេ ។

> នៅចំពោះតុលាការនេះ អំណាចស៊ើបសួរប្រគល់ឲ្យតែសហចៅក្រមស៊ើបអង្កេតឯករាជ្យពីរនាក់ប៉ុណ្ណោះ និងមិនប្រគល់ឲ្យភាគីទេ។ ពុំមានបទប្បញ្ញត្តិដែលអនុញ្ញាតឲ្យភាគីបំពេញការស៊ើបសួរជំនួសឲ្យ [សហចៅក្រមស៊ើបអង្កេត] ឡើយ តែភាគីអាចត្រូវបានអនុញ្ញាតឲ្យស៊ើបអង្កេតនៅក្នុងប្រព័ន្ធនីតិវិធីដទៃទៀត ។ ជាការពិតតាមវិធាន៥៥(១០) និងវិធាន៥៨(៦) ភាគីមានសិទ្ធិស្នើឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ(...)[2]។

៣. នៅថ្ងៃទី៥ ខែ មេសា ឆ្នាំ ២០១១ លោកមេធាវីការពារ Michiel PESTMAN បានសាកសួរនៅក្នុងកិច្ចប្រជុំរៀបចំសវនាការថា តើការហាមឃាត់មិនឲ្យមេធាវីការពារក្តីស៊ើបអង្កេតដោយឯករាជ្យនៅតែជាធរមានដែរ ឬយ៉ាងណា[3]។

---

[1] ឯកសារ **E-161.1**, "ឧបសម្ព័ន្ធ ក- ឯកសារទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា [DC-CAM] ដែលត្រូវបានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ ១-២០ របស់សហព្រះរាជអាជ្ញា តាមវិធាន៨០(៣) បញ្ជីឯកសារដំណាក់កាលដំបូង E109/4.1'' ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ ERN 00770511-00770624 ។

[2] ឯកសារ **A-110/1** "លិខិតពី កសចស ទៅកាន់លោកមេធាវី សុន អរុណ និង Michiel PESTMAN, ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២00៨ ERN 00157729-00157730 នៅទំព័រទី២ (បញ្ជាក់បន្ថែម) ។

[3] ឯកសារ **E-1/2.1** "ប្រតិចារិតសវនាការ" ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ERN 00664215-00664345, p. 116:3-14.។

៤. មកទល់នឹងថ្ងៃនេះ ក្រុមមេធាវីការពារក្តីមិនទទួលបានការឆ្លើយតបដោយអង្គជំនុំជម្រះទៅនឹងសំណើសុំការបញ្ជាក់នេះនៅឡើយទេ ។ អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីចាំបាច់សន្មតថា ការហាមឃាត់ចំពោះការស៊ើបអង្កេតដោយឯករាជ្យ នៅជាធរមាននៅឡើយ ។

## ខ. ការចងក្រងឯកសារដោយ DC-CAM

៥. នៅថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារក្តីបានដាក់ “សារណាបន្ថែមទាក់ទងទៅនឹងសំណើសុំការបញ្ជាក់ប្រភព/ខ្សែរសង្វាក់នៃការរក្សាឯកសាររបស់ DC-CAM[4] ដែលបានស្នើសុំឱ្យអង្គជម្រះស្នើ (យ៉ាងខ្លី)ទៅ DC-CAM ឱ្យផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រភព និងខ្សែរសង្វាក់នៃការរក្សាឯកសាររបស់ DC-CAM ដែល កសព មានបំណងយកមកប្រើ ។

៦. នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួន “សេចក្តីលើសេចក្តីជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែល ពាក់ព័ន្ធទៅនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ” ដែលចែងនៅផ្នែកពាក់ព័ន្ធ:

> ២៧. នៅពេលមានការស្នើសុំ មជ្ឈមណ្ឌល DC-CAM នឹងព្យាយាមតាមដានរកប្រភពដើមនៃ ឯកសារ ។ ប៉ុន្តែ លោក ឆាំង យុ បានផ្តល់សក្ខីកម្មថា ពុំមានភាគីណាមួយនៃសំណុំរឿង ០០២ បានធ្វើសំណើមកមជ្ឈមណ្ឌល DC-CAM ដើម្បីស្នើសុំឯកសារដើមឡើយ។ ជាងនេះទៅទៀត មេធាវីការពារក្តីជនជាប់ចោទ នួន ជា បានទទួលស្គាល់ថា ពួកគេពុំចោទថាមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកបានកែប្រែឯកសារឡើយ[5]។ ថ្វីបើមេធាវីការពារក្តីអះអាងថាមជ្ឈមណ្ឌលឯកសារកម្ពុជាពុំទាន់មានភាពល្អិតល្អន់គ្រប់គ្រាន់ក្នុងការបញ្ជាក់ប្រភព និងយថាភាពនៃ

---

[4] ឯកសារ **E-1/39.1/1** “សារណាបន្ថែមទាក់ទងទៅនឹងសំណើសុំការបំភ្លឺពីដើមកំណើត/ខ្សែរសង្វាក់នៃការគ្រប់គ្រងឯកសារនៅ DC-CAM” ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00777270-00777276 (“សារណាបន្ថែម”) ។

[5] មេធាវីការពារក្តីកត់សម្គាល់ថាការបង្ហាញជំហរបែបនេះ គឺមិនត្រឹមត្រូវទេទាក់ទងទៅនឹងលទ្ធភាពនៃការកែប្រែឯកសារដោយ DC-CAM នោះ ។ ទាក់ទងនឹងបញ្ហានេះ មេធាវីការពារក្តីបានអធិប្បាយតែក្នុងអំឡុងពេលស្តាប់សក្ខីកម្មរបស់សាក្សី ឆាំង យុ ប៉ុណ្ណោះ នៅពេលដែលមេធាវីការពារក្តីបានលើកឡើង “ច្បាស់ណាស់ ខ្ញុំពិតជាមិនបានលើកឡើងថា DC-CAM បានកែប្រែឯកសារ” ។ មេធាវីការពារក្តីគ្រាន់តែលើកឡើងនៅក្នុងសវនាការថាខ្លួនមិនបានចោទប្រកាន់ DC-CAM ថាបានកែប្រែឯកសារនោះ ។ ឯកសារ E-1/38.1 “ប្រតិចារិតសវនាការ” ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១២ ERN 00777033-00777149, pp. 88-20-89:4.2 ។

ឯកសារក៏ដោយ ក៏សក្ខីកម្មរបស់លោក វ៉ាន់ថាន់ ដារ៉ា និងលោក ឆាំង យុ ពុំមានលក្ខណៈអាចឲ្យជំទាស់តវ៉ាបានឡើយ ។

២៨. ផ្អែកលើសក្ខីកម្មរបស់លោក ឆាំង យុ និងលោក វ៉ាន់ថាន់ ដារ៉ា អង្គជំនុំជម្រះយល់ឃើញ ថាវិធីសាស្ត្រ ដែល DC-CAM បានប្រើប្រាស់ក្នុងការទទួលបានឯកសារ ការធ្វើប័ណ្ណសារ និងការរក្សាទុកឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ អាចឲ្យជឿជាក់បាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថាឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រភពមកពីមជ្ឈមណ្ឌល DC-CAM ត្រូវបានទទួលការសន្មតមមឋមនៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព) ផងដែរ។ ទោះបីព័ត៌មានទាក់ទងនឹងប្រភព និងខ្សែរសង្វាក់ នៃការថែរក្សាឯកសារ ពុំចាំបាច់ត្រូវបានផ្តល់ពាក់ព័ន្ធទៅនឹងឯកសារនីមួយៗដែលត្រូវបានស្នើ សុំឲ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ដំណើរការដែលត្រូវបានអនុវត្តដោយ DC-CAM ពុំផ្តល់នូវការយល់សមហេតុសមផលណាមួយដែលថា ឯកសារនានាដែលចេញពីប្រភពនេះ អាចស្ថិតនៅក្រោមការកែប្រែ បន្ថំ ឬក្លែងក្លាយឡើយ។ ឯកសារដើមនៃឯកសារទាំងអស់នេះ ត្រូវបាន DC-CAM រក្សាទុក ហើយអាចបានស្នើសុំពិនិត្យឯកសារទាំងអស់នេះ នៅពេលមានបញ្ហាព្រួយបារម្ភជាក់ស្តែង ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃឯកសារចម្លងដែលមាននៅក្នុងសំណុំរឿង ឬពាក់ព័ន្ធទៅនឹងប្រភព ឬភាពអាចជឿជាក់បាននៃឯកសារជាក់លាក់ណាមួយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា ពុំមានមូលដ្ឋានណាមួយឡើយ ដើម្បីពិនិត្យពិចារណាទៅលើសំណើរបស់មេធាវីជនជាប់ចោទ នួន ជា ស្នើសុំព័ត៌មានបន្ថែមដែលត្រូវបានរក្សាទុកនៅក្នុង database របស់ DC-CAM ឬសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំផ្តល់ឯកសារដើមទាំងអស់របស់ DC-CAM សម្រាប់ថេរវេលានៃសវនាការ[6]។

## III. អង្គហេតុដែលពាក់ព័ន្ធ

៧. ចាប់តាំងពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨ មេធាវីការពារក្តី បានប្រតិបត្តិក្រោមបំរាមការបំពេញកិច្ចស៊ើបអង្កេតដោយឯករាជ្យរបស់ កសចស ។ មកទល់នឹងថ្ងៃនេះ អង្គជំនុំជម្រះមិនទាន់លុបចោលបំរាមនេះនៅឡើយទេ ។

៨. ការព្រួយបារម្ភអំពីខ្សែរសង្វាក់នៃការរក្សា និងប្រភពនៃឯកសារ ដែលនឹងយកមកប្រើប្រាស់នៅក្នុងករណីនេះ និងដោយដឹងពីការហាមឃាត់អំពីការបំពេញកិច្ចស៊ើបអង្កេតដោយឯករាជ្យ មេធាវីការពារ

---

[6] ឯកសារ **E-185** "សេចក្តីសេចក្តីជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ERN 00798257-00798273 នៅកថាខណ្ឌទី ២៧-២៨ (អក្សរក្នុងលេខយោងដើមលុបចោល)។

ក្ដីជាញឹកញយបានជ្រើសរើសវិធីសាស្ត្រសមហេតុសមផលបំផុតចំពោះបញ្ហានេះ។ មេធាវីការពារ អនុវត្តតាមប្រព័ន្ធដែលបង្កើតឡើងនៅ អវតក និងបានស្នើអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ (កសចស) ឲ្យបញ្ជាក់អំពីខ្សែរសង្វាក់នៃការរក្សា និងប្រភពនៃឯកសារ ដែល កសចស មានបំណង សំអាងនៅពេលចេញដីកាដំណោះស្រាយ ។

៩. សំណើលើកទីមួយរបស់មេធាវីការពារក្ដីទាក់ទងនឹងបញ្ហានេះ ដាក់នៅពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ មកម្ល៉េះ ដែលមកទល់នឹងថ្ងៃនេះមានរយៈពេលបួនឆ្នាំកន្លះកន្លងមកហើយ[7]។ សំណើនេះមិនគ្រាន់តែ ត្រូវបានដាក់ទាន់ពេលប៉ុណ្ណោះទេ តែថែមទាំងមានន័យយ៉ាងច្បាស់ទៀតផង។ នៅក្នុងសំណើនេះមេធា វីការពារក្ដីបានស្នើ កសចស "ថាឯកសារណាមួយ និងឯកសារទាំងអស់ដែល កសចស យកមកប្រើ ប្រាស់ក្នុងគោលបំណងណាមួយ ត្រូវតែបានបញ្ជាក់ពីយថាភាព ហើយខ្សែរសង្វាក់នៃការគ្រប់គ្រង ត្រូវតែបានស៊ើបអង្កេត និងចុះកំណត់ត្រាឲ្យបានត្រឹមត្រូវ"[8]។

១០. ទោះជាយ៉ាងនេះក្ដី រហូតមកទល់នឹងថ្ងៃនេះព័ត៌មានត្រឹមត្រូវទាក់ទងនឹងប្រភព និងខ្សែរសង្វាក់នៃការ រក្សាឯកសាររបស់ DC-CAM នៅតែពុំមាន បើទោះបីជាយើងខ្ញុំបានដាក់សំណើដដែលៗ និងទាន់ ពេលវេលាសុំព័ត៌មានបែបនេះក៏ដោយ[9]។ ក្នុងការបដិសេធសំណើរបស់យើងខ្ញុំសុំព័ត៌មានបន្ថែមទាក់ ទងនឹងខ្សែរសង្វាក់នៃការរក្សា និងប្រភពនៃឯកសារ (ដែលព័ត៌មាននេះអាចរកបាននៅ DC-CAM) អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ដូចខាងក្រោម ទាក់ទងនឹងវិធីសាស្ត្ររបស់មេធាវីការពារក្ដីចំពោះ ឯកសារ DC-CAM:

> ឯកសារដើមនៃឯកសារទាំងអស់នេះ ត្រូវបាន DC-CAM រក្សាទុក ហើយអាចបានស្នើសុំពិនិត្យឯកសារទាំង អស់នេះ នៅពេលមានបញ្ហាព្រួយបារម្ភជាក់ស្ដែងពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃឯកសារចម្លងដែលមាននៅក្នុង សំណុំរឿង ឬពាក់ព័ន្ធទៅនឹងប្រភព ឬភាពអាចជឿជាក់បាននៃឯកសារជាក់លាក់ណាមួយ[10]។

---

[7] ឯកសារ **A-110** "លិខិតដែលមានកម្មវត្ថុ "ការបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ERN 00157351-00157352 ។

[8] ឯកសារ **A-110** "លិខិតដែលមានកម្មវត្ថុ "ការបំពេញកិច្ចស៊ើបសួរ" ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ERN 00157351-00157352 ។

[9] សារណាបន្ថែមនៅកថាខណ្ឌទី១០-១៣ (រៀបរាប់ពីសំណើរបស់មេធាវីការពារក្ដីទៅ កចសច នៅទូទាំងការស៊ើបសួរ រួមទាំង សំណើលើកទី១៧ សុំបំពេញកិច្ចស៊ើបសួរដែលដាក់នៅឆ្នាំ២០០៩ "សុំឲ្យកំណត់អត្តសញ្ញាណប្រភពឯកសារជាក់លាក់នីមួយៗ ដែល មានបំណងយកមកសំអាងនៅក្នុងដីកាដំណោះស្រាយ និងសុំឲ្យបង្កើតខ្សែរសង្វាក់នៃការគ្រប់គ្រង---ចាប់ផ្ដើមពីទទួលបានរហូតដល់ ផ្ដល់មកឲ្យ កចសច--ចំពោះសម្ភារៈជាក់លាក់នៃឯកសារភស្តុតាង) ។

[10] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅកថាខណ្ឌទី២៨ ។

ហើយៈ

នៅពេលមានការស្នើសុំ DC-CAM នឹងព្យាយាមតាមដានរកប្រភពដើមនៃឯកសារ[11]។

១១. ជាពិសេសអង្គជំនុំជម្រះបានស្តីបន្ទោសមេធាវីការពារក្តីចំពោះការមិនស្នើសុំពិនិត្យមើលប្រភពដើមនៃឯកសារដែលមានប្រភពមកពីមជ្ឈមណ្ឌល DC-CAM នៅដំណាក់កាលដំបូងនៃការស៊ើបសួរ។ មូលហេតុនេះ គឺមិនត្រឹមត្រូវ និងមិនអាចជឿបានៈ

- ដូចដែលបានពិភាក្សារួចមកហើយ មេធាវីការពារក្តីត្រូវហាមឃាត់មិនឱ្យបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង ហើយដូច្នេះមេធាវីការពារក្តីសន្មតយ៉ាងត្រឹមត្រូវថា ទំនាក់ទំនងដោយផ្ទាល់ជាមួយប្រភពដ៏សំខាន់តែមួយគត់នៃភស្តុតាងប្រឆាំងនឹងកូនក្តីរបស់ខ្លួន ដែលនៅគ្រានោះ កសចស ខ្លួនឯងមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងប្រភពទាំងនោះទាក់ទងនឹងឯកសារដូចគ្នា នឹងរំលោភដោយផ្ទាល់ទៅលើបំរាមចំពោះការស៊ើបសួរដោយមេធាវីការពារក្តីរបស់ កសចស។ នៅក្រោមប្រព័ន្ធដែល បង្កើតឡើងដោយ កសចស ដែលមានគោលដៅយ៉ាងច្បាស់ថាមេធាវីការពារក្តីមិនអាចត្រួតពិនិត្យដោយឯករាជ្យថា តើឯកសារនានាដែល កសចស មានបំណងយកមកសំអាងនៅក្នុងការចេញដីកាដំណោះស្រាយ ជាឯកសារពិតដែរ ឬយ៉ាងណា ។ ការយល់ឃើញណាមួយផ្សេងទៀត មិនបានពិចារណាទៅលើតថភាព (ដែនកំណត់ផ្នែកច្បាប់) នៃដំណាក់កាលស៊ើបសួរ[12]។
- ដូចដែលបានពិភាក្សារួចមកហើយ មេធាវីការពារក្តីបានចាត់តែវិធានការដើម្បីពិនិត្យយថភាព ខ្សែរសង្វាក់ និងប្រភពនៃឯកសាររបស់ DC-CAM ដែលមេធាវីអាចរក

---

[11] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះនៅកថាខណ្ឌទី២៧ ។

[12] ការដែលថាមេធាវីការពារក្តីបានប្រាស្រ័យទាក់ទងមជ្ឈមណ្ឌល DC-CAM ច្រើនលើកច្រើនដង និងថាមជ្ឈមណ្ឌ DC-CAM បានជួយគាំទ្រដល់បញ្ហាជាក់លាក់ដទៃទៀតដែលមិនជាប់ពាក់ព័ន្ធ ក៏វាមិនអាចបង្កើតជាកាតកិច្ចផ្លូវច្បាប់ដើម្បីចូលរួមពាក់ព័ន្ធការត្រួតពិនិត្យ យថាភាពនៃឯកសារទាំងអស់ ដែលមាននៅក្នុងសំណុំរឿងបានដែរ (បើទោះបីជាសន្មតថាមជ្ឈមណ្ឌល DC-CAM មានឆន្ទៈផ្តល់ជំនួយបែបនេះមកដល់មេធាវីការពារក្តីក៏ដោយចុះ)។

បាននៅក្រោមប្រព័ន្ធ ដែលបង្កើតឡើងដោយ កសចស តាមរយៈស្នើសុំ កសចស ឱ្យបំពេញកិច្ចអ្វីមួយតែប៉ុណ្ណោះ ។

- មេធាវីការពារក្ដីមិនអាចដំណើរការពិនិត្យឱ្យបានទូលំទូលាយនូវប្រភព/ខ្សែរសង្វាក់នៃការថែររក្សាឯកសាររាប់ពាន់ ដែលដាក់នៅក្នុងសំណុំរឿងក្នុងអំឡុងពេលស៊ើបសួរឡើយ ។ មេធាវីការពារក្ដីពិតជាពុំមានពេលវេលា និងធនធានដើម្បីបំពេញកិច្ចការនេះបាននោះទេ។ កសចស ជាមួយនឹងអ្នកស៊ើបអង្កេតដ៏ច្រើនរបស់ខ្លួនទាំងខ្មែរ និងបរទេស ហើយក៏ជាការិយាដែលបំពាក់ទៅដោយសម្ភារៈ និងធនធានមនុស្សគ្រប់គ្រាន់បំផុតដែរសម្រាប់ស៊ើបសួរបែបនេះ[13]។
- ដូចដែលបានវែកញែកក្នុង "សារណាបន្ថែម" របស់យើងខ្ញុំ វាជារឿងសមហេតុផលដែលថា ភាគីមួយដែលចង់សំអាងលើឯកសារជាក់លាក់ណាមួយ ឬផ្ដល់ឯកសារជាភស្តុតាង ត្រូវផ្ដល់ឱ្យភាគីដទៃទៀតនូវព័ត៌មានពាក់ព័ន្ធនឹងប្រភព និងខ្សែរសង្វាក់នៃការថែរក្សាឯកសារ។ ទាំងនេះជាការពិត ប្រសិនបើព័ត៌មានបែបនេះអាចរកបាន (ដូចដែលត្រូវបានអះអាងក្នុងករណីពាក់ព័ន្ធទៅនឹងឯកសាររបស់ DC-CAM)។ ដូច្នេះហើយ ក្នុងករណីនេះវាអាស្រ័យលើ កសព ដែលត្រូវផ្ដល់ព័តមាននេះទៅកាន់ភាគី។ គេមិនអាចនៅតែអះអាងថា មេធាវីការពារក្ដីមានកាតព្វកិច្ចផ្លូវច្បាប់ត្រូវពិនិត្យ ឬលាតត្រដាងដោយឯករាជ្យនូវព័ត៌មានទាក់ទងនឹងភស្តុតាងដែលផ្ដល់ឱ្យដោយភាគីដទៃទៀតឡើយ។ បញ្ហានេះមិនត្រឹមតែកើតចេញពីការវាយតម្លៃដែលមិនគ្រប់ជ្រុងជ្រោយលើទឡ្ហីករណ៍ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាបន្ទុកនៃភស្តុតាងដែលធ្លាក់លើ កសព ផងដែរ: ប្រសិនបើ កសព ចង់ឱ្យផ្ដន្ទាទោស នួន ជា ដោយឈរលើមូលដ្ឋាននៃភស្តុតាងដែលពួកគេបានផ្ដល់ឱ្យតុលាការ កសព ត្រូវមានបន្ទុកក្នុងការបង្ហាញឱ្យឃើញថាភស្តុតាងរបស់ខ្លួន គឺគួរឱ្យជឿជាក់។ ទូទៅជាងនេះទៅទៀត ក្ដីបារម្ភទៅលើខ្សែ

[13] ការិយាល័យបន្ទាប់ពី កសចស គឺ កសព ដែលបំពាក់ទៅដោយសម្ភារៈ និងធនធានមនុស្សគ្រប់គ្រាន់បំផុតក្នុងការស៊ើបសួរ ។ កសព មិនត្រឹមតែមានបុគ្គលិកដែលមានសមត្ថភាព ដែលអាចជួយដល់ការស៊ើបសួរប៉ុណ្ណោះទេ តែពួកគេក៏មានចំណេះដឹងដោយផ្ទាល់ជាមួយនឹងនីតិវិធី មជ្ឈមណ្ឌល DC-CAM ផងដែរ យើងមិនគួរភ្លេចទេថា គឺ កសព ដែលសម្រេចផ្នែកលើឯកសារជាច្រើនមកពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងដីកាបញ្ជូនរឿងទោះស៊ើបសួរ, សូមមើលខាងក្រោម ជើងទំព័រ ១៤។

សង្វាក់នៃការរក្សាទុក និងប្រភពនៃឯកសារដែលនឹងត្រូវយកមកប្រើប្រាស់ជាភស្តុតាង មិនមែនត្រឹមតែជាក្តីកង្វល់របស់មេធាវីការពារក្តីតែម្នាក់ប៉ុណ្ណោះទេ។ កសព និង កសចស ហើយឥឡូវនេះ អង្គជំនុំជម្រះក៏មានកតាព្វកិច្ចផ្នែកច្បាប់ដែលត្រូវបារម្ភអំពីបញ្ហានេះដូចគ្នា។

- ក្តីកង្វល់នេះគឺបានលេចចេញឡើង *តាមរយៈ (និងបន្ទាប់តែពី)* ការសាកសួរលោកវ៉ាន់ថាន់ ពៅដារ៉ា និងលោក ឆាំង យុ ទាក់ទងទៅនឹងប្រភព និង ខ្សែសង្វាក់នៃការរក្សាទុកឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាតែប៉ុណ្ណោះ។ ពិតណាស់ការសាកសួរសាក្សីទាំងនេះ គឺដើម្បីលាតត្រដាងអំពីក្តីបារម្ភដែលដំបូងឡើយមេធាវីការពារក្តីមិនទាន់យល់ច្បាស់។ មេធាវីការពារក្តីមិនគួរមានកាតព្វកិច្ចដែលត្រូវតែដឹងឲ្យបានលម្អិតនូវនីតិវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងកំហុសឆ្គងរបស់មជ្ឈមណ្ឌលនេះឡើយ។ តាមពិតទៅការបង្ហាញឲ្យឃើញនូវព័ត៌មានបែបនេះ គឺជាគោលបំណងមួយក្នុងចំណោមគោលបំណងដទៃទៀតនៃការចោទសួរបដិសាក្សី[14]។ ដោយសារតែគេបានដឹងតាមរយៈការចោទសួរបដិសាក្សីថា កំហុសឆ្គងដ៏ធ្ងន់ធ្ងរពិតជាបានកើតឡើងមែន វាគឺជាការទទួលខុសត្រូវរបស់ភាគី (និងអង្គជំនុំជម្រះ) ក្នុងការស្វែងរកបន្ថែមទៀតអំពីទំហំនៃកំហុសឆ្គងទាំងនេះ។
- សេចក្តីសម្រេចរបស់អង្គជំនុំជម្រះហាក់បីដូចជារិះគន់ការជំទាស់របស់មេធាវីការពារក្តី ទាក់ទងនឹងការខ្វះភាពជាក់លាក់ពាក់ព័ន្ធនឹងឯកសារជាក់លាក់។ ប៉ុន្តែ ជំហររបស់មេធាវីការពារក្តី គឺច្បាស់ណាស់: យើងសូមជំទាស់នឹងយថាភាព និង/ឬក៏ការទទួល

[14] នេះជាការពិតទោះបីក្នុងប្រព័ន្ធច្បាប់ណាក៏ដោយ ប៉ុន្តែការសង្កេតនេះរិ តតែមានការពាក់ព័ន្ធជាងមុនទៅទៀត ដោយពិចារណាទៅលើបញ្ហាដែលថាមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាភាគីសហប្រតិបត្តិការដ៏សំខាន់មួយរបស់ កសព និង កសចស មិនមែនជាមួយមេធាវីការពារក្តីឡើយ។ កសព និង កសចស មានការពាក់ព័ន្ធដ៏ទូលំទូលាយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនជាមួយមេធាវីការពារក្តីឡើយ ហើយប្រសិនបើមានកាតព្វកិច្ចចំពោះភាគីណាមួយ (ហើយមេធាវីការពារក្តីយល់ឃើញថាមាន) ដើម្បីធ្វើឲ្យខ្លួនយល់ច្បាស់អំពីវិធីធ្វើការផ្ទៃក្នុងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នោះវាគឺជាកាតព្វកិច្ចរបស់ស្ថាប័ន អវតក ទាំងពីរនេះ មិនមែនមេធាវីការពារក្តីឡើយ។ (ជាថ្មីម្តងទៀត ការពិតដ៏សាមញ្ញមួយដែលថាមានការទំនាក់ទំនឹងមិនពាក់ព័ន្ធមួយចំនួនរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងមេធាវីការពារក្តី មិនបានធ្វើឲ្យមេធាវីការពារក្តី ក្លាយជាអ្នកជំនាញខាងវិធីសាស្ត្រប្រមូលឯកសាររបស់មជ្ឈមណ្ឌលនេះឡើយ។

យកឯកសារណាមួយដែលមិនមានខ្សែសង្វាក់នៃការរក្សាទុកឯកសារគ្រប់គ្រាន់ ឬមិនមានព័ត៌គ្រប់គ្រាន់ទាក់ទងនឹងប្រភពនៃឯកសារ។ សំខាន់ជាងនេះទៅទៀត យើងនឹងបញ្ជាក់ឲ្យច្បាស់អំពីការជំទាស់នេះ ប្រសិនបើយើងទទួលបានព័ត៌មានទាក់ទងនឹងអត្ថិភាព ឬភាពមិនមាននៃទិន្នន័យបែបនេះ ។ ប្រព័ន្ធ database របស់ DC-CAM មានទិន្នន័យដែលអាចចូលមើលបានរួចទៅហើយ ដែលនឹងអនុញ្ញាតឲ្យភាគី កំណត់ថា តើព័ត៌មានទាក់ទងនឹងខ្សែសង្វាក់នៃការរក្សាទុកឯកសារ និងប្រភពនៃឯកសារពិតជាមានដែរឬយ៉ាងណា[15]។ ដូចដែលបានគូសបញ្ជាក់កាលពីលើកមុនព័ត៌មាន បែបនេះមិនត្រឹមតែចាំបាច់ដើម្បីកំណត់អំពីយថាភាព និងភាពអាចទទួលយកបាននៃ ឯកសារប៉ុណ្ណោះទេ ប៉ុន្តែវាក៏ចាំបាច់ នៅពេលវាយតម្លៃពីតម្លៃបង្ហាញផ្លូវនៃភស្តុតាង ទៅរកការពិតផងដែរ ហើយអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ក៏បានទទួលស្គាល់ពីបញ្ហានេះដែរ[16]។

១២. ឥឡូវនេះ ដោយសារក្តីបារម្ភទាក់ទងនឹងប្រភព និងខ្សែរសង្វាក់នៃការថែរក្សាទុកឯកសាររបស់ DC-CAM រិតតែធ្ងន់ធ្ងរឡើងជាងមុន នៅពេលដែលអង្គជំនុមជម្រះបានចាប់ផ្តើមពឹងផ្អែកលើឯកសារទាំងនោះក្នុងអំឡុងកិច្ចនីតិវិធី ទោះបីជាប្រភព និងខ្សែរសង្វាក់នៃការរក្សាទុកឯកសារទាំងនេះមានភាពស្រពិចស្រពិលទាំងស្រុងក៏ដោយ។ ជារៀងរាល់ថ្ងៃការអនុវត្តន៍បែបនេះចេះតែបន្តទៅមុខ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់កូនក្តីយើងខ្ញុំកំពុងទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

## IV. សេចក្តីសន្និដ្ឋាន

១៣. អាស្រ័យហេតុនេះ មេធាវីការពារក្តីនឹង ទាក់ទងដោយខ្លួនឯងទៅ DC-CAM ដើម្បីពិនិត្យ ខ្សែរសង្វាក់នៃការរក្សាទុកឯកសារ និងភាពពាក់ព័ន្ធនៃឯកសារដែល កសព មានបំណងយកមកសំអាងដូចដែល

[15] មេធាវីការពារក្តីសូមអះអាងថានេះគ្រាន់តែជាជំហានដំបូងក្នុងការវិភាគអំពីខ្សែសង្វាក់នៃការរក្សាទុកឯកសារ និងប្រភពដើម នៃឯកសារតែប៉ុណ្ណោះ។ ថាតើឯកសារដែលមាននៅក្នុងប្រព័ន្ធទិន្នន័យ *គ្រប់គ្រាន់* ឬអត់នោះ អាចត្រូវបានវាយតម្លៃក្រោយពេលដែលវាត្រូវបានពិនិត្យរួចតែប៉ុណ្ណោះ។

[16] ឯកសារលេខ **E-162** អនុស្សរណៈ: "អង្គជំនុំជម្រះឆ្លើយតបទៅនឹង E114, E114/1, E131/1/9, E131/6, E136 and E158, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២, ERN 00772276-00772277,កថាខណ្ឌ ៧។

បានរៀបរាប់ក្នុងឯកសារ E-161.1 ដែលកិច្ចការដែល កសចស និង កសព គួរតែបានធ្វើជាច្រើនឆ្នាំមកហើយ[17]។

១៤. មេធាវីការពារក្ដីយល់ថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ[19] ចង់មានន័យថាវិធីសាស្ត្របែបនេះមិនបានរំលោភការហាមឃាត់របស់ កសចស លើការស៊ើបអង្កេតដោយឯករាជ្យដោយមេធាវីការពារក្ដីឡើយ។ មេធាវីការពារក្ដីជឿជាក់ថាអង្គជំនុំជម្រះនឹងជូនដំណឹងដល់យើងខ្ញុំ ប្រសិនបើការយល់ឃើញបែបនេះមិនត្រឹមត្រូវ។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** Michel PESTMAN & Victor KOPPE

[17] គួរកត់សម្គាល់ផងដែរថាមេធាវីការពារក្ដីនៅតែមិនទាន់ត្រូវបានបំពាក់ធនធានឲ្យបានគ្រប់គ្រាន់ដើម្បីធ្វើការស៊ើបអង្កេតក្នុងលក្ខណៈស៊ីជម្រៅ។

[19] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ២៧ ដល់២៨។